## ក្រសួងមុខងារសាធារណៈ

## គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

# របាយការណ៍
# ស្តីពី
# លទ្ធផលបូកសរុបការងារប្រចាំឆ្នាំ២០១៦
# និងទិសដៅអនុវត្តការងារឆ្នាំ២០១៧
# របស់គណៈកម្មាធិការកែទម្រង់
# រដ្ឋបាលសាធារណៈ


លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦

www.mcs.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ: ៦០៤៦ មស.គគរ

# របាយការណ៍
# ស្តីពី
# លទ្ធផលបូកសរុបការងារប្រចាំឆ្នាំ២០១៦ និងទិសដៅអនុវត្តការងារឆ្នាំ២០១៧ របស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានរៀបចំសិក្ខាសាលាបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៦ និងទិសដៅអនុវត្តការងារឆ្នាំ២០១៧ រយៈពេលពីរថ្ងៃ ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី៨-៩ ខែធ្នូ ឆ្នាំ២០១៦ នៅសណ្ឋាគារឆ្នេរថ្មី ខេត្តព្រះសីហនុ ក្រោមអធិបតីភាព **ឯកឧត្តម កិត្តិបណ្ឌិត រដ្ឋមន្ត្រី** ក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ។

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម កិត្តិបណ្ឌិត រដ្ឋមន្ត្រី** បានថ្លែងមតិស្វាគមន៍ចំពោះវត្តមានរបស់ ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ ដែលបានចូលរួមក្នុងសិក្ខាសាលាស្តីពីការបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និងការកំណត់ផែនការសកម្មភាពជាអាទិភាព និងបញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ សម្រាប់ឆ្នាំ២០១៧ នាពេលនេះ។ ជាមួយគ្នានេះដែរ **ឯកឧត្តម កិត្តិបណ្ឌិត រដ្ឋមន្ត្រី** បានធ្វើការលើកទឹកចិត្ត និងកោតសរសើរដល់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងមុខងារសាធារណៈ និងឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកានៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដែលបានខិតខំបំពេញការងារទទួលបានលទ្ធផលជាវិជ្ជមាន និងមានកិច្ចសហការខ្ពស់ ដូចបានកំណត់នៅក្នុងរបាយការណ៍វឌ្ឍនភាពការងារឆ្នាំ២០១៦។

ទន្ទឹមនឹងសមិទ្ធផលសម្រេចបាន ក៏នៅមានសកម្មភាពការងារមួយចំនួនពុំទាន់បានអនុវត្តពេញលេញនៅឡើយដែលនឹងត្រូវលើកយកមកពិភាក្សា និងរកដំណោះសម្រាប់ការអនុវត្តនៅឆ្នាំ២០១៧ខាងមុខ។ ការមិនបានអនុវត្តបានពេញលេញនៅសកម្មភាពដែលបានកំណត់ទាំងនោះ ដោយសារមានបញ្ហាប្រឈមមួយចំនួនក្នុងនោះរួមមាន៖

<u>**បញ្ហាប្រឈមទី១**</u> គឺមានការជាប់ពាក់ព័ន្ធទៅនឹងកម្រិតភាពនៃហិរញ្ញវត្ថុ ធនធានមនុស្ស និងប្រសិទ្ធភាពនៃការគ្រប់គ្រងពេលវេលា។ ត្រង់ចំណុចនេះ **ឯកឧត្តម កិត្តិបណ្ឌិត** បានធ្វើការកត់សម្គាល់ថា អង្គភាពទាំងអស់ក្រោមឱវាទក្រសួងមុខងារសាធារណៈមានសកម្មភាពការងារច្រើន និងបានអនុវត្តសកម្មភាពការងារទាំងនោះរៀងៗខ្លួនដែលធ្វើឲ្យមានការចំណាយច្រើនទាំងពេលវេលា ធនធានមនុស្ស និងថវិកា។ ក្នុងការដោះស្រាយបញ្ហាទាំងនេះ **ឯកឧត្តម កិត្តិបណ្ឌិតរដ្ឋមន្ត្រី** បានស្នើឱ្យអង្គសិក្ខាសាលាធ្វើការពិភាក្សាដើម្បីរកដំណោះស្រាយរួមគ្នាលើបញ្ហាប្រឈមដែលបានលើកឡើង។ ជាមួយគ្នានេះផងដែរ **ឯកឧត្តម កិត្តិបណ្ឌិត រដ្ឋមន្ត្រី** បានជម្រាបជូន



ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

ជាឧទាហរណ៍ដល់អង្គសិក្ខាសាលានូវបទពិសោធន៍ដែលយើងបានអនុវត្តនាពេលកន្លងមក ហើយបានបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ពេលវេលា ថវិកា និងធនធានមនុស្សរួមមាន ៖

**ទី១.** ការអនុវត្តការងារជាលក្ខណៈក្រុមការងារគម្រោង ក្នុងការសិក្សាអំពីមុខងារ រចនាសម្ព័ន្ធ និងនីតិវិធីនៃការបំពេញការងាររបស់អង្គភាពធនធានមនុស្សនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការអនុវត្តការងារជាក្រុមការងារគម្រោងនេះ បានអនុញ្ញាតឱ្យមានការបន្សុីគ្នារវាងសកម្មភាពការងារនៃក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការ និងការងាររបស់លេខាធិការដ្ឋាននៃគណៈកម្មាការកែទម្រង់រដ្ឋបាលសាធារណៈ ដែលបានជួយបង្កើនប្រសិទ្ធភាពក្នុងការប្រើប្រាស់ថវិកា ធនធានមនុស្ស និងពេលវេលា។

**ទី២.** ការសហការគ្នារវាងលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងសាលាភូមិន្ទរដ្ឋបាលក្នុងការរៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុង និងវគ្គបណ្តុះបណ្តាលមន្ត្រីជាន់ខ្ពស់ ជាពិសេស ការសហការនេះ បានលើកកម្ពស់នូវប្រសិទ្ធភាពនៃការចំណាយទាំងថវិកា និងធនធានមនុស្សផងដែរ។

ផ្អែកលើបទពិសោធន៍ទាំងនេះ **ឯកឧត្តម កិត្តិបណ្ឌិត រដ្ឋមន្ត្រី** បានស្នើឱ្យអង្គសិក្ខាសាលាពិចារណាលើវិធីសាស្ត្រអនុវត្តការងារដូចនេះ។ លើសពីនេះ **ឯកឧត្តម កិត្តិបណ្ឌិត រដ្ឋមន្ត្រី** ក៏បានមានប្រសាសន៍ថាក្នុងឆ្នាំ ២០១៧ ខាងមុខនេះ យើងត្រូវសម្រេចសកម្មភាពអាទិភាពរបស់អង្គភាពទាំងអស់ក្រោមឱវាទក្រសួងមុខងារសាធារណៈបញ្ចូលគ្នាដោយយកកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈជាគោល។

**<u>បញ្ហាប្រឈមទី២</u>** គឺភាពខ្វះចន្លោះនៃការចូលរួមអនុវត្តសកម្មភាពការងារដែលបានដាក់ចេញប្រកបដោយស្មារតីសហការ ភាពជាម្ចាស់ និងការទទួលខុសត្រូវ។ កន្លងមកហើយសង្កេតឃើញថា ការចូលរួមជំរុញនិងការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈដែលបានដាក់ចេញ មានដូចជា៖ ការអនុវត្តគោលនយោបាយនិងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល និងការផ្តល់សេវាសាធារណៈនៅមានកម្រិតនៅឡើយ។ ត្រង់ចំណុចនេះ **ឯកឧត្តម កិត្តិបណ្ឌិត រដ្ឋមន្ត្រី** បានស្នើឲ្យមានការចូលរួមពីឯកឧត្តម លោកជំទាវ ដែលជាសមាជិក សមាជិកានៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បន្តចូលរួមជំរុញការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈនិងបង្កើនស្មារតីភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់លើការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរៀងខ្លួនៗ ដើម្បីឲ្យកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ ទទួលបានជោគជ័យ។

ជាកិច្ចបន្ត **ឯកឧត្តម គង់ សុភី** អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈនិងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានរាយការណ៍ពីវឌ្ឍនភាពការងាររយៈពេលមួយឆ្នាំរបស់អគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ និងលេខាធិការដ្ឋាន ដែលសម្រេចបានលើវិស័យទាំង៣ រួមមាន៖ (១)ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ (២)ការអភិវឌ្ឍសមត្ថភាពស្ថាប័ន ការកែលម្អការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស (៣)ការកែទម្រង់ប្រព័ន្ធបៀវត្ស។ ជាមួយគ្នានេះដែរ **ឯកឧត្តម គង់ សុភី** ក៏បានលើកឡើងពីសកម្មភាព និងបញ្ហាប្រឈមមួយចំនួនដែលកើតមាន ក្នុងនោះមាន៖ បញ្ហាវត្តមានរបស់មន្ត្រីរាជការ បញ្ហាធនធានមនុស្ស បញ្ហាថវិកា បញ្ហាពេលវេលាក្នុងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ ជាដើម ។

បន្ទាប់ពីស្តាប់នូវមតិណែនាំ របាយការណ៍បូកសរុបលទ្ធផល និងកិច្ចពិភាក្សារយៈពេលពីរថ្ងៃរួចមក អង្គសិក្ខាសាលាបានឯកភាពទៅលើបញ្ហាប្រឈម និងដំណោះស្រាយ និងទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០១៧ ខាងមុខ ដូចតទៅ៖

**១. បញ្ហាប្រឈម**

នៅក្នុងការអនុវត្តមានពេលកន្លងមក គឺមានការជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន រួមមាន៖

- ការងារអាទិភាពមានច្រើននៅក្នុងការអនុវត្តដែលពិបាកនឹងសម្រេចបានតាមការគ្រោងទុក
- កម្លាំងធនធានមនុស្សមិនបានប្រមូលផ្តុំ គឺស្ថិតនៅរាយប៉ាយដែលធ្វើឱ្យផលិតភាព ប្រសិទ្ធភាពនៃការអនុវត្តការងារនៅមានកម្រិត
- ថវិកាសម្រាប់គាំទ្រដល់ដំណើរការអនុវត្តកម្មវិធីជាតិនៅមានការយឺតយ៉ាវ នីតិវិធីច្រើន ស្មុគស្មាញ ដែលធ្វើឱ្យការទម្លាក់ និងផ្តល់ថវិកាសម្រាប់ការអនុវត្តមិនបានទាន់ពេលវេលា
- ការគាំទ្រពីដៃគូអភិវឌ្ឍទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុនៅមានតិចតួច
- សមត្ថភាពមន្ត្រីរាជការនៅក្នុងការចូលរួមអនុវត្តការងារកែទម្រង់នៅមានកម្រិតទាំងសមត្ថភាព ចំណេះដឹងជំនាញ និងការគ្រប់គ្រង
- ការចូលរួម និងការប្តេជ្ញាចិត្តរបស់មន្ត្រីរាជការនៅក្នុងការងារកែទម្រង់នៅមានកម្រិត
- គុណផល និងវិន័យនៅក្នុងការបំពេញការងាររបស់មន្ត្រីរាជការសាធារណៈ នៅមានកម្រិត
- បញ្ហាពេលវេលា គឺទាមទាររយៈពេលយូរដើម្បីបានឃើញ និងបានយល់អំពីសមិទ្ធផលការងារកែទម្រង់រដ្ឋបាលសាធារណៈ
- សមត្ថភាពក្នុងការគ្រប់គ្រងការអនុវត្តការងារមិនបានក្លាយជាប្រព័ន្ធការងារ (យន្តការនៃការគ្រប់គ្រង)
- ការចូលរួមអនុវត្តការងារកែទម្រង់របស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅមានកម្រិត
- ការលើកទឹកចិត្តទាំងថវិកានិងមិនមែនថវិកានៅតែជាបញ្ហាសម្រាប់អ្នកដឹកនាំ និងអ្នកអនុវត្តការងារកែទម្រង់
- ការចូលរួមសហការ និងការគាំទ្រពីក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងផ្ទៃក្នុងអង្គភាពនៅមានកម្រិត
- ចំណេះដឹងរបស់មន្ត្រីរាជការអំពីទស្សនទាន និងកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈនៅមានកម្រិត
- យន្តការ និងប្រព័ន្ធរាយការណ៍នៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃនៅមានកម្រិត។

**២. ដំណោះស្រាយ**

ទន្ទឹមនឹងការជួបប្រទះនូវបញ្ហាប្រឈមជាច្រើនដូចដែលបានរៀបរាប់ពីខាងលើ គណៈកម្មាធិការកែទម្រង់ រដ្ឋបាលសាធារណៈ ក៏បានឯកភាពដាក់ចេញនូវដំណោះស្រាយសមស្រប មួយចំនួន ដូចខាងក្រោម៖

(១) ដំណោះស្រាយជាក់លាក់ក្នុងការអនុវត្តផែនការសកម្មភាព ក្នុងនោះត្រូវផ្តោតទៅលើ៖

- គួរកំណត់អាទិភាពលើការងារអាទិភាព
- ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវមានផែនការសកម្មភាពជាក់លាក់ក្នុងការជំរុញអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ

- ក្រសួងមុខងារសាធារណៈ គួរផ្តល់ការគាំទ្រផ្នែកប្រឹក្សាយោបល់ និងការបណ្តុះបណ្តាលដល់មន្ត្រីរាជការនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិអំពីទស្សនទានការងារកែទម្រង់រដ្ឋបាលសាធារណៈ
- ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅតាមក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវចូលរួមអនុវត្តការងារកែទម្រង់ឱ្យបានសកម្ម
- ត្រូវមានប្រព័ន្ធវាយតម្លៃលើការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីរាជការ។

(២) ដំណោះស្រាយក្នុងការងារសម្របសម្រួល ត្រូវផ្តោតទៅលើចំណុចមួយចំនួន រួមមានៈ

- ត្រូវមានការចែករំលែកចំណេះដឹងពាក់ព័ន្ធនឹងការងារកែទម្រង់រដ្ឋបាលសាធារណៈពិសេសជំរុញការផ្សព្វផ្សាយ និងបណ្តុះបណ្តាលឲ្យបានស៊ីជម្រៅនិងសមស្របតាមពេលវេលា ដល់គ្រប់អ្នកពាក់ព័ន្ធនូវគោលការណ៍ លិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការងារកែទម្រង់រដ្ឋបាលសាធារណៈ
- ការសម្របសម្រួលត្រូវគោរពតាមគោលការណ៍៖ សមត្ថភាព ការយល់ដឹង ឆន្ទៈ ការចូលរួម និងទំនាក់ទំនង
- ត្រូវមានរបបប្រជុំជាទៀងទាត់ប្រចាំត្រីមាសឬឆមាស រវាងសមាជិកគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធាណៈដើម្បីពិនិត្យមើលលើវឌ្ឍនភាពការងារដោយមានការចូលរួមផងដែរពីដៃគូអភិវឌ្ឍ។

(៣) ដំណោះស្រាយពាក់ព័ន្ធទៅនឹងយន្តការនិងប្រព័ន្ធរាយការណ៍ ក្នុងនោះរួមមាន៖

- ត្រូវមានយន្តការដាក់លាក់ក្នុងការផ្តល់របាយការណ៍
- ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវមានសមត្ថកិច្ច និងទំនាក់ទំនងជាមួយអង្គភាពជំនាញ ដើម្បីយកទិន្នន័យមកដាក់ក្នុងរបាយការណ៍
- ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវមានគណនេយ្យភាពក្នុងការផ្តល់របាយការណ៍វឌ្ឍនភាពការងារជាទៀងទាត់។

## ៣. ទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០១៧

អង្គសិក្ខាសាលា បានឯកភាពលើការកំណត់ផែនការសកម្មភាពអាទិភាពសម្រាប់២០១៧ មានដូចខាងក្រោម៖

### ៣.១. ការកែលម្អគុណភាពសេវាសាធារណៈ ត្រូវអនុវត្តដូចតទៅៈ

- រៀបចំបង្កើត និងដាក់ឱ្យអនុវត្តមជ្ឈមណ្ឌលទូរព័ត្ទបន្ទាន់ (Call Centre)
- រៀបចំនិងដាក់ឱ្យអនុវត្តច្រកទ្វារអេឡិកត្រូនិចផ្តល់ព័ត៌មានសេវាសាធារណៈ(Public Service Gateway)
- រៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីសេវាសាធារណៈ
- ត្រួតពិនិត្យនិងកែលម្អនីតិវិធី និងយន្តការក្នុងការផ្តល់សេវាសាធារណៈរបស់ក្រសួង ស្ថាប័ន និងថ្នាក់ក្រោមជាតិ

- រៀបចំបង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃគុណភាពសេវាសាធារណៈ ដោយមានការឯកភាពគ្នារវាងក្រសួងមុខងារសាធារណៈ និងក្រសួងសាមី (មួយក្រសួងម្តង)
- រៀបចំ និងដាក់ឲ្យដំណើរការច្រកចេញចូលតែមួយនៅក្រសួងមុខងារសាធារណៈ
- រៀបចំ និងដាក់ឲ្យអនុវត្តប្រព័ន្ធវាយតម្លៃស្ថាប័នរដ្ឋ និងការផ្តល់ពានរង្វាន់ និងប្រាក់រង្វាន់ដល់ស្ថាប័នសាធារណៈដែលមានស្នាដៃល្អ។

**៣.២. ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស ត្រូវអនុវត្ត ដូចតទៅ៖**

- រៀបចំការពិពណ៌នាមុខតំណែងក្នុងមុខងារសាធារណៈក្នុងរចនាសម្ព័ន្ធគ្រប់គ្រង
- រៀបចំការពិនិត្យប្រតិបត្តិការឡើងវិញនៅតាមក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំអភិវឌ្ឍ និងពង្រីកការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាក្នុងការគ្រប់គ្រងធនធានមនុស្ស នៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- រៀបចំនិងដាក់ឱ្យអនុវត្តក្របខណ្ឌគតិយុត្តនៃការបណ្តុះបណ្តាលជាកាតព្វកិច្ចសម្រាប់មន្ត្រីរាជការស៊ីវិល និងកែលម្អកម្មវិធីបណ្តុះបណ្តាល និងការអភិវឌ្ឍធនធានមនុស្សនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ពង្រីកវិសាលភាពនៃការបណ្តុះបណ្តាលមន្ត្រីជាន់ខ្ពស់ មធ្យម និងមន្ត្រីក្របខណ្ឌថ្មី
- ជំរុញការអនុវត្តព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំព្រះរាជក្រឹត្យស្តីពីគោលការណ៍រួមនៃការគ្រប់គ្រងធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ
- រៀបចំអង្គមន្ត្រីរាជការស៊ីវិល និងមុខតំណែងវិជ្ជាជីវៈ
- រៀបចំបង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល និងប្រព័ន្ធលើកទឹកចិត្ត
- រៀបចំបង្កើតមូលដ្ឋានទិន្នន័យសម្រាប់គ្រប់គ្រងសមត្ថភាពជំនាញរបស់មន្ត្រីរាជការស៊ីវិល និងប្រវត្តិសមត្ថភាពការងារ
- រៀបចំក្រមសីលធម៌មន្ត្រីរាជការស៊ីវិល

**៣.៣. ការកែទម្រង់ប្រព័ន្ធបៀវត្ស ត្រូវអនុវត្ត ដូចតទៅ៖**

- ពង្រីកការអនុវត្តប្រព័ន្ធបញ្ជូន និងទទួលឯកសារបៀវត្សតាមប្រព័ន្ធអេឡិកត្រូនិចឱ្យបានទូទាំងប្រទេស
- រៀបចំអនុក្រឹត្យស្តីពីការកម្រិតរបបម៉ោង កំណត់ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមសម្រាប់បុគ្គលិកអប់រំនៅតាមគ្រឹះស្ថានសាធារណៈ
- សិក្សាទៅលើលទ្ធភាពនៃការដំឡើងប្រាក់វេនយាមសម្រាប់វិស័យសុខាភិបាល
- រៀបចំដំឡើងប្រាក់បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារនិងប្រាក់ឧបត្ថម្ភផ្សេងៗតាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល

**៣.៤. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ**

- រៀបចំកិច្ចប្រជុំគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីអនុម័តលើរបាយការណ៍វឌ្ឍនភាពការងារឆ្នាំ២០១៦ នៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ និងទិសដៅបន្តសម្រាប់ឆ្នាំ២០១៧

- ត្រូវរៀបចំកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យមើលលើវឌ្ឍនភាពនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ
- ចុះតាមដាននិងត្រួតពិនិត្យលើការអនុវត្តលិខិតបទដ្ឋានគតិយុត្តដែលបានដាក់ឱ្យអនុវត្តមានដូចជា៖(១) កំណត់របនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (២)ការរៀបចំការពិពណ៌នាមុខតំណែង (៣)ការពង្រឹងវត្តមានមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា ជាដើម
- ចុះតាមដាន និងត្រួតពិនិត្យចំនួនមន្ត្រីរាជការក្រសួងសុខាភិបាល។

លទ្ធផលនៃអង្គសិក្ខាសាលានេះ នឹងក្លាយជាធាតុចូល សម្រាប់ការធ្វើបច្ចុប្បន្នភាពទៅលើរបាយការណ៍វឌ្ឍនភាពការងារឆ្នាំ២០១៦នៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ និងលើកទិសដៅការងារអាទិភាពឆ្នាំ២០១៧ មុននឹងដាក់ឆ្លងកិច្ចប្រជុំគណៈកម្មាធិការកែទម្រង់រដ្ឋបាល សាធារណៈអនុម័ត។

អង្គសិក្ខាសាលា ត្រូវបានបញ្ចប់នៅវេលាម៉ោង១១:៥០ នាទីនៅថ្ងៃ០៩ ខែធ្នូ ឆ្នាំ២០១៦ ប្រកបដោយកិច្ចសហប្រតិបត្តិកាខ្ពស់ បរិយាកាសសប្បាយរីករាយសិទ្ធិស្នាល និងលទ្ធផលវិជ្ជមាន ។/

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦
**អគ្គនាយក និងជាប្រធានលេខាធិការដ្ឋានគ.ក.រ**

**គង់ សុភី**

រាជធានីភ្នំពេញ ថ្ងៃទី២៨ខែ ធ្នូ ឆ្នាំ២០១៦
បានឃើញ និងឯកភាព
**រដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការ**
**កែទម្រង់រដ្ឋបាលសាធារណៈ**

**ពេជ្រ ប៊ុនធិន**